ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ ......០៥៥......ជ.ទ.ម

# សេចក្តីជូនដំណឹង
# ស្តីពី មហាសន្និបាតភាគហ៊ុនិក លើកទី១២
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ជ្រាបថា៖ រ.ទ.ស.ភ នឹងរៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី១២ **នៅថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨** ត្រូវនឹង**ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤** ចាប់ពីម៉ោង **៨:០០នាទីព្រឹក** នៅទីស្នាក់ការ រ.ទ.ស.ភ និងតាមប្រព័ន្ធអនឡាញ (ZOOM) ដែលមានរបៀបវារៈដូចខាងក្រោម៖

១. ការចុះវត្តមាន
២. ប្រកាសហេតុ
៣. បទបង្ហាញស្តីពី៖
  ក- របាយការណ៍លទ្ធផលអាជីវកម្ម ឆ្នាំ២០២៣
  ខ- ទិសដៅអាជីវកម្ម ឆ្នាំ២០២៤
  គ- សំណួរ-ចម្លើយ
៤. កម្មវិធីបោះឆ្នោតតាមប្រព័ន្ធអនឡាញ
  ក- ការបោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក
  ខ- ការបោះឆ្នោតអនុម័តលាភការរបស់ក្រុមប្រឹក្សាភិបាល
៥. មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណរបស់ប្រធានគណៈអធិបតី

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ (កាលបរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិក លើកទី១២) ត្រូវបញ្ជាក់ការចូលរួមជាមួយ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) នៅរៀងរាល់ថ្ងៃធ្វើការ **ចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤** ដល់ **ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤** ចាប់ពីម៉ោង **៨:០០នាទី** ដល់ម៉ោង **១៦:៣០នាទី**។

★ **បញ្ជាក់ ៖**

១. ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១២ របស់ រ.ទ.ស.ភ ប៉ុន្តែមិនបានធ្វើការបញ្ជាក់ការចូលរួមរបស់ខ្លួនជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី តាមការកំណត់ខាងលើនេះនឹងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១២ របស់ រ.ទ.ស.ភ នោះទេ។



អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

